# ស្ថានទូតសហរដ្ឋអាមេរិក ភ្នំពេញ, កម្ពុជា

សេចក្តីប្រកាសពត៌មាន ក្នុងឆ្នាំ២០១៤

Share

បកប្រែ: English

## ទីភ្នាក់ងារ USAID សម្ពោធគំរោងអនាម័យនិងអាហារូបត្ថម្ភចំរុះនៅកម្ពុជា (០៨ កញ្ញា ២០១៤)

ចេញថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១៤




លោកស្រី Rollins បានមានប្រសាសន៍ថា “សន្តិសុខស្បៀងនិងអាហារូបត្ថម្ភគឺជាបញ្ហាពីរក្នុងចំណោមបញ្ហាបន្ទាន់បំផុតដែលប្រទេសកម្ពុជាប្រឈមជាមួយ។

កម្មវិធីថ្មីមួយរបស់រដ្ឋាភិបាលសហរដ្ឋអាមេរិកដែលមានឈ្មោះថាអាហារូបត្ថម្ភនិងអនាម័យ(NOURISH) នឹងប្រយុទ្ធប្រឆាំងកង្វះអាហារូបត្ថម្ភក្នុងចំណោមកុមារកម្ពុជា។នៅថ្ងៃទី៨ខែកញ្ញាឆ្នាំ២០១៤ឯកឧត្តមឧបនាយករដ្ឋមន្ត្រី យឹម ឆៃលីនិងលោកស្រី Denise Rollins ឧបការីស្តីទីអភិបាលការិយាល័យសំរាប់ទ្វីបអាស៊ីរបស់ទីភ្នាក់ងារសហរដ្ឋអាមេរិកសំរាប់ការអភិវឌ្ឍន៍អន្តរជាតិ (USAID) បានប្រកាសសម្ពោធនូវគំរោងអនាម័យនិងអាហារូបត្ថម្ភចំរុះរបស់USAID ដែលមានរយៈពេល៥ឆ្នាំក្នុងទឹកប្រាក់ចំនួន ១៦,២៥ លានដុល្លាអាមេរិក។




អត្រាមរណៈភាពរបស់កុមារដែលស្ថិតក្នុងអាយុក្រោម៥ឆ្នាំនៅកម្ពុជានៅពេលនេះមានចំនួន៥៤នាក់ក្នុងចំណោមកូនក្មេងដែលកើតមករស់ចំនួន១០០០នាក់ហើយជិត៣៥ភាគរយនៃការស្លាប់របស់កុមារបណ្តាលមកពីទំរង់ផ្សេងៗនៃកង្វះអាហារូបត្ថម្ភ។កុមារដែលមានកង្វះអាហារូបត្ថម្ភមិនត្រឹមតែប្រឈមនឹងការស្លាប់ ការឈឺនិងការឆ្លងជំងឺច្រើនតែប៉ុណ្ណោះទេតែថែមទាំងមានកង្វះប្រាជ្ញាវៀងវៃមានការលូតលាស់យឺតហើយរៀនមិនសូវបានច្រើនឆ្នាំនៅសាលា។ការសិក្សាស្រាវជ្រាវរបស់ធនាគារអភិវឌ្ឍន៍អាស៊ីនិងស្ថាប័នដទៃទៀតបានបង្ហាញផងដែរថាកង្វះអាហារូបត្ថម្ភអាចធ្វើអោយកំណើនសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាមានការយឺតយ៉ាវ។

លោកស្រី Rollins បានមានប្រសាសន៍ថា “សន្តិសុខស្បៀងនិងអាហារូបត្ថម្ភគឺជាបញ្ហាពីរក្នុងចំណោមបញ្ហាបន្ទាន់បំផុតដែលប្រទេសកម្ពុជាប្រឈមជាមួយ។យើងមានការជឿជាក់ថាគំរោងនេះដែលនឹងត្រូវបានអនុវត្តដោយការធ្វើការសហការយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរថ្នាក់ជាតិនិងថ្នាក់មូលដ្ឋាននឹងជួយកាត់បន្ថយកំរិតនៃកង្វះអាហារូបត្ថម្ភក្នុងចំណោមកុមារកម្ពុជាដែលជាការនាំអោយពួកគេមានការចាប់ផ្តើមបានល្អទៅរកការមានជីវិតមួយប្រកបដោយជោគជ័យ”។

កម្មវិធី NOURISH របស់ទីភ្នាក់ងារ USAID នៅកម្ពុជានឹងត្រូវបានអនុវត្តដោយសហព័ន្ធនៃអង្គការសង្គ្រោះកុមារ (Save the Children Federation, Inc.) នឹងជួយដល់ប្រជាជនកម្ពុជាចំនួនប្រហែល៥០០,០០០នាក់នៅតាមសហគមន៍ជនបទក្នុងខេត្តបាត់ដំបង ពោធិសាត់ និងសៀមរាប ។ កម្មវិធី NOURISH ជាផ្នែកមួយនៃកិច្ចប្រឹងប្រែងដ៏សំខាន់របស់រដ្ឋា

ភិបាលសហរដ្ឋអាមេរិក ក្នុងការកែលំអអាហារូបត្ថម្ភតាមរយៈគំរោងគំនិតផ្តួចផ្តើមផ្តល់អាហារសំរាប់អនាគត (Feed the Future Initiative) ដែលក្នុងនោះរួមមានកំណើននៃមុខដំណាំ និងផលិតភាពកសិកម្ម ការផ្តល់អាហារដូចជានៅតាមសាលារៀនការអប់រំស្តីពីអនាម័យនិងភាពស្អាត និងកំណែលំអលើប្រព័ន្ធសុខាភិបាលដែលយកចិត្តទុកដាក់ចំពោះកុមារនិងម្តាយដោយរួមមានការកសាងមណ្ឌលសុខភាពថ្មីៗនិងមន្ទីរពិសោធន៍ផ្នែកពេទ្យ និងការបណ្តុះបណ្តាលបុគ្គលិកជំនាញពេទ្យជាដើម។

គំរោង NOURISH មានការយកចិត្តទុកដាក់ជាពិសេសលើស្រ្តីមានផ្ទៃពោះនិងកុមារក្រោមអាយុ២ឆ្នាំហើយបង្កើនមុខអាហារនិងគុណភាពអាហារព្រមទាំងកែលំអលទ្ធភាពប្រើប្រាស់កន្លែងអនាម័យ កន្លែងលាងដៃ និងចំរោះទឹកនៅក្នុងមូលដ្ឋាន។ គំរោង NOURISH ថែមទាំងផ្តល់សេវាសំរាប់ពេលមុននិងក្រោយការឆ្លងទន្លេនៅមណ្ឌលសុខភាពនិងកម្មវិធីជំរុញការធំធាត់នៅតាមមណ្ឌលសុខភាពនិងសហគមន៍។

ប្រវត្តិទីភ្នាក់ងារ USAID ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៦១ ដោយលោកប្រធានាធិបតីអាមេរិក John F. Kennedy ហើយដើរតួនាទីជាទីភ្នាក់ងារនាំមុខគេក្នុងការផ្តល់ជំនួយបរទេសរបស់រដ្ឋាភិបាលសហរដ្ឋអាមេរិក ។ ចាប់តាំងពីឆ្នាំ ១៩៩២ មកទីភ្នាក់ងារ USAID បានចំណាយថវិកាប្រហែល ១ ពាន់លានដុល្លាអាមេរិកសំរាប់ការអភិវឌ្ឍន៍នៅកម្ពុជា។

ចំពោះព័ត៌មានបន្ថែមស្តីពីគំរោង NOURISH សូមទាក់ទង

Erika Lutz, MPH

Chief of Party,NOURISH

Save the Children/Cambodia

Email: erika.lutz@savethechildren.org

គេហទំព័រនេះគ្រប់គ្រងដោយក្រសួងការបរទេសសហរដ្ឋអាមេរិក។ ទស្សនៈឬគោលនយោបាយស្តីពីភាពជាឯកជន របស់អត្ថបទឬគេហទំព័រភ្ជាប់ ដែលនៅក្រៅគេហទំព័ររបស់យើង មិនឆ្លុះបញ្ចាំងពីទស្សនៈរបស់រដ្ឋាភិបាលអាមេរិកទេ។